# លក្ខខណ្ឌទូទៅនៃការប្រើប្រាស់សេវាអេស៊ីលីដាអ៊ីនធើណែត សម្រាប់ក្រុមហ៊ុន ឬអង្គភាព

## Terms and Conditions of ACLEDA Corporate Internet Banking

## ១ លក្ខខណ្ឌរួម

លក្ខខណ្ឌទូទៅនៃសេវាអេស៊ីលីដាអ៊ីនធើណែត សម្រាប់ក្រុមហ៊ុន ឬអង្គភាព គឺជាកិច្ចសន្យា ឬកិច្ចព្រមព្រៀងរវាងធនាគារ អេស៊ីលីដា ភីអិលស៊ី និងអតិថិជន ក្នុងការធ្វើប្រតិបត្តិការធនាគារតាមរយៈសេវាអេស៊ីលីដាអ៊ីនធើណែត សម្រាប់ក្រុមហ៊ុន ឬអង្គភាព ។ លក្ខខណ្ឌនេះបង្កើតឡើងសម្រាប់ប្រើអមជាមួយ "ប័ណ្ណផ្សព្វផ្សាយ" និង "តារាងថ្លៃសេវា និងការកំណត់ប្រតិបត្តិការ សេវាអេស៊ីលីដាអ៊ីនធើណែត សម្រាប់ក្រុមហ៊ុន ឬអង្គភាព" ។

សូមអានកិច្ចសន្យានេះ ឲ្យបានយល់ច្បាស់ មុននឹងចុះហត្ថលេខាលើពាក្យស្នើសុំប្រើប្រាស់សេវាអេស៊ីលីដាអ៊ីនធើណែត សម្រាប់ក្រុមហ៊ុន ឬអង្គភាព ។ នៅពេលលោក-លោកស្រី បានចុះហត្ថលេខា ឬបានទទួលលក្ខខណ្ឌទូទៅនៃសេវាអេស៊ីលីដាអ៊ីនធើណែត មានន័យថា លោក-លោកស្រី យល់ព្រមគ្រប់លក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យា និងទទួលខុសត្រូវទាំងស្រុងលើប្រតិបត្តិការធនាគារ តាមរយៈសេវាអេស៊ីលីដាអ៊ីនធើណែតនេះ ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី សូមរក្សាសិទ្ធិក្នុងការកែប្រែលក្ខខណ្ឌ និងថ្លៃសេវានៃសេវាអេស៊ីលីដាអ៊ីនធើណែត សម្រាប់ក្រុមហ៊ុន ឬអង្គភាព នៅពេលណាមួយដោយអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ ធនាគារនឹងជូនដំណឹងទៅលោក-លោកស្រី ក្នុងករណីដែលការកែប្រែនេះ ធ្វើឲ្យប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់លោក-លោកស្រី ។

**ការប្រើប្រាស់ពាក្យពេចន៍ ៖**

- នៅក្នុងលក្ខខណ្ឌនៃការប្រើប្រាស់នេះ ពាក្យថា "លោក-លោកស្រី" "របស់លោក-លោកស្រី" សំដៅដល់អតិថិជន ឬម្ចាស់គណនីដែលប្រើប្រាស់សេវាអេស៊ីលីដាអ៊ីនធើណែត សម្រាប់ក្រុមហ៊ុន ឬអង្គភាព ជាមួយធនាគារ អេស៊ីលីដា ភីអិលស៊ី ។
- ពាក្យថា "យើង" "របស់យើង" និង "ធនាគារ" សំដៅដល់ធនាគារ អេស៊ីលីដា ភីអិលស៊ី ។
- សេវាអេស៊ីលីដាអ៊ីនធើណែត សម្រាប់ក្រុមហ៊ុន ឬអង្គភាព តទៅហៅកាត់ថា "សេវាអេស៊ីលីដាអ៊ីនធើណែត" ។
- ប្រព័ន្ធអេស៊ីលីដាអ៊ីនធើណែត (ACLEDA Internet System) : គឺជាប្រព័ន្ធដែលអភិវឌ្ឍឡើងដោយធនាគារ អេស៊ីលីដា ភីអិលស៊ី សម្រាប់ផ្តល់ជូនអតិថិជនក្រុមហ៊ុន/អង្គភាព ធ្វើប្រតិបត្តិការធនាគារ តាមរយៈសេវាអេស៊ីលីដាអ៊ីនធើណែត ។
- អ្នកអភិបាលប្រព័ន្ធក្រុមហ៊ុន ឬអង្គភាព (Corp-Admin/Corporate Administration User) : សំដៅដល់នាយក ឬម្ចាស់ក្រុមហ៊ុន ឬម្ចាស់គណនី ឬអ្នកតំណាង ក្រុមហ៊ុន/អង្គភាព ដែលបានទទួលសិទ្ធិពេញលេញប្រើប្រាស់ប្រព័ន្ធ សិទ្ធិគ្រប់គ្រងចាត់ចែងប្រតិបត្តិការ ឬសិទ្ធិគ្រប់គ្រងចាត់ចែងអ្នកប្រើប្រាស់ ។ អ្នកអភិបាលប្រព័ន្ធមាន ០២ ប្រភេទគឺ អ្នកអភិបាលប្រព័ន្ធធម្មតា និងអ្នកអភិបាលប្រព័ន្ធស្វ័យត ។
- អ្នកប្រើប្រាស់សេវាអេស៊ីលីដាអ៊ីនធើណែត (Corporate User) : សំដៅដល់សមាជិកគណនីក្រុមហ៊ុន ឬអ្នកមិនមែនសមាជិកគណនី ដែលបានទទួលសិទ្ធិប្រទានពីនាយក ឬម្ចាស់ក្រុមហ៊ុន ឬម្ចាស់គណនី ឬអ្នកតំណាងក្រុមហ៊ុន ដើម្បីប្រើប្រាស់ប្រព័ន្ធអេស៊ីលីដាអ៊ីនធើណែត ។
- ប្រតិបត្តិការស្វ័យប្រវត្តិ (Straight Through Process) : គឺជាប្រភេទប្រតិបត្តិការសេវាធនាគារដែលដំណើរការតាមប្រព័ន្ធអេស៊ីលីដាអ៊ីនធើណែតបានសម្រេចភ្លាមៗ បន្ទាប់ពីការបញ្ចូលទិន្នន័យ ត្រួតពិនិត្យ និង/ឬអនុម័តទិន្នន័យរួចដោយអតិថិជន ហើយមិនឆ្លងកាត់ការត្រួតពិនិត្យ និងអនុម័តពីភាគីធនាគារឡើយ ។
- ប្រតិបត្តិការមិនស្វ័យប្រវត្តិ (Non-straight Through Process) : គឺជាប្រភេទប្រតិបត្តិការសេវាធនាគារដែលដំណើរការតាមប្រព័ន្ធអេស៊ីលីដាអ៊ីនធើណែត ហើយឆ្លងកាត់ការត្រួតពិនិត្យ និងអនុម័តពីភាគីធនាគារ បន្ទាប់ពីទទួលបាននូវប្រតិបត្តិការដែលស្នើឡើងដោយអតិថិជន ។

## ២ លក្ខខណ្ឌក្នុងការចុះឈ្មោះប្រើប្រាស់សេវាអេស៊ីលីដាអ៊ីនធើណែត សម្រាប់ក្រុមហ៊ុន ឬអង្គភាព

២.១ លោក-លោកស្រី ត្រូវបើកគណនីធនាគារ និងផ្តល់លិខិត/ឯកសារសម្គាល់អត្តសញ្ញាណ សម្រាប់គាំទ្រការបើកគណនីទៅតាមនីតិវិធីដែលកំណត់ដោយធនាគារ អេស៊ីលីដា ភីអិលស៊ី ។

២.២ បំពេញទម្រង់ពាក្យស្នើសុំប្រើប្រាស់សេវាអេស៊ីលីដាអ៊ីនធើណែត ក្នុងនាមជាអ្នកអភិបាលប្រព័ន្ធ ដោយត្រូវចុះហត្ថលេខា ឬផ្តិតស្នាមមេដៃស្តាំ ឲ្យបានត្រឹមត្រូវ និងច្បាស់លាស់ ។ ពាក្យស្នើសុំប្រើប្រាស់សេវា គឺជាកិច្ចព្រមព្រៀងដំបូង ដែលប្រើអមជាមួយលក្ខខណ្ឌនេះ សម្រាប់អនុវត្តក្នុងដំណើរការសេវាអេស៊ីលីដាអ៊ីនធើណែត ។

២.៣ បន្ទាប់ពីការចុះឈ្មោះរួចភ្លាម ៖

- លោក-លោកស្រី នឹងទទួលបាន User ID និងលេខសម្ងាត់បណ្តោះអាសន្ន ដែលផ្ញើទៅកាន់អាសយដ្ឋានអ៊ីម៉ែលរបស់លោក-លោកស្រីដែលជាម្ចាស់គណនីក្រុមហ៊ុន ឬអ្នកទទួលសិទ្ធិប្រទាន ។ លោក-លោកស្រី ត្រូវផ្លាស់ប្តូរលេខសម្ងាត់នេះភ្លាម ក្នុងពេលចូលប្រព័ន្ធអេស៊ីលីដាអ៊ីនធើណែត លើកដំបូង ។
- តូកិន (Token) គឺជាឧបករណ៍សុវត្ថិភាពមួយប្រភេទនៃសេវាអេស៊ីលីដាអ៊ីនធើណែត ដែលតម្រូវឲ្យអ្នកប្រើប្រាស់ ប្រើដើម្បីបង្ការសុវត្ថិភាពក្នុងការចូលប្រព័ន្ធ និងបញ្ជាក់លើប្រតិបត្តិការផ្ទេរប្រាក់ ឬទូទាត់ ។ តូកិន មានទម្រង់ជាឧបករណ៍ ៖
  - ACLEDA Hard Token: គឺជាឧបករណ៍ប្រើសម្រាប់បង្កើតលេខសម្ងាត់ OTP (One Time Password) ។
  - ACLEDA Authentication: គឺជាកម្មវិធីដែលអាចទាញយកពី App Store ឬ Play Store បញ្ចូលក្នុងទូរស័ព្ទដែលប្រតិបត្តិការដោយ iOS ឬ Android ។ លោក-លោកស្រីត្រូវចុះឈ្មោះដោយខ្លួនឯងផ្ទាល់ និងបំពេញព័ត៌មានដូចជា User ID, E-mail និងលេខទូរស័ព្ទ រួចចុច "SUBMIT" ប្រព័ន្ធនឹងផ្ញើលេខសម្ងាត់ចុះឈ្មោះ (Registration Code) ចំនួន "៨ខ្ទង់" ចូលលេខទូរស័ព្ទដៃ និងអ៊ីម៉ែលរបស់លោក-លោកស្រី ដើម្បីវាយបញ្ចូលទៅក្នុងទូរស័ព្ទបញ្ជាក់លើប្រតិបត្តិការចុះឈ្មោះ ។ Registration Code មានសុពលភាពប្រើប្រាស់ក្រោយការបង្កើតឡើងមានរយៈពេល ២៣វិនាទី ករណីលេខសម្ងាត់នេះអស់សុពលភាព លោក-លោកស្រីអាចចុច "Resend Verification Code" នៅលើ Status ដើម្បីទាញយកលេខសម្ងាត់ជាថ្មីបានតាមតម្រូវការ ។

២.៤ លោក-លោកស្រី ត្រូវធ្វើលិខិតចាត់តាំងជាផ្លូវការ ទាំងសមាជិកគណនី និងមិនមែនសមាជិកគណនី ឲ្យមានមុខងារជាអ្នកអភិបាលប្រព័ន្ធ (Normal-Admin/Self-Admin) និង Corporate User ដោយបញ្ជាក់ពីអត្តសញ្ញាណឲ្យបានច្បាស់លាស់។ រាល់ឯកសារសម្គាល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែន ដែលត្រូវបញ្ចូល ឬ Upload ទៅក្នុងប្រព័ន្ធ ត្រូវតែជាច្បាប់ដើម និងមានសុពលភាពប្រើប្រាស់យ៉ាងតិចរយៈពេលបីខែ គិតចាប់ពីថ្ងៃដែលធនាគារបានទទួល ។ ចំពោះអ្នកអភិបាលប្រព័ន្ធ និង Corporate User ដែលជាជនបរទេសស្នាក់នៅប្រទេសកម្ពុជា ត្រូវផ្តល់បន្ថែមនូវវីសាដែលនៅមានសុពលភាព ។

## ៣ ប្រតិបត្តិការធនាគារដែលអាចធ្វើបាន

បន្ទាប់ពីចុះឈ្មោះសេវាអេស៊ីលីដាអ៊ីនធើណែត បានសម្រេច លោក-លោកស្រីអាចធ្វើប្រតិបត្តិការសេវាធនាគារនៅក្នុងប្រព័ន្ធអេស៊ីលីដាអ៊ីនធើណែតបាន តាមរយៈកុំព្យូទ័រផ្ទាល់ខ្លួន (Desktop ឬ Laptop) ដូចខាងក្រោម ៖

### ៣.១ ការត្រួតពិនិត្យមើលព័ត៌មានធនាគារ

- ពិនិត្យមើលអត្រាប្តូរប្រាក់,
- ពិនិត្យមើលព័ត៌មានគណនីបញ្ញើ-សន្សំ ដូចជា : សមតុល្យគណនីសង្ខេប, សមតុល្យគណនីលម្អិត, របាយការណ៍គណនី, របាយការណ៍ប្រតិបត្តិការប្រចាំថ្ងៃ និងរបាយការណ៍មូលប្បទានបត្រ,
- ពិនិត្យមើលកម្រិតបន្ទាត់ឥណទាន ។

### ៣.២ ការស្នើសុំប្រើប្រាស់ផលិតផល-សេវាកម្មផ្សេងៗ

- ស្នើសុំបង្ខាំងចំនួនទឹកប្រាក់,
- ស្នើសុំដោះបង្ខាំងចំនួនទឹកប្រាក់,
- ស្នើសុំដំណើរការគណនីនៅស្ងៀមនិងគ្មានសកម្មភាព,
- ស្នើសុំបញ្ឈប់មូលប្បទានបត្រ,
- ចំពោះសេវាផ្សេងៗទៀត នឹងដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅពេលក្រោយ ។

### ៣.៣ សេវាទូទាត់

- សេវាទូទាត់វិក្កយបត្រ អគ្គិសនី, ទឹក, ទូរស័ព្ទ, អ៊ីនធើណែត ឬសាលារៀន ។ល។,
- សេវាបើកប្រាក់បៀវត្សរ៍,
- សេវាទូទាត់ជាកញ្ចប់,
- សេវាបញ្ជាអចិន្ត្រៃយ៍ថេរ,
- សេវាទូទាត់ឲ្យអ្នកផ្គត់ផ្គង់,
- ចំពោះសេវាទូទាត់ផ្សេងៗទៀត នឹងដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅពេលក្រោយ ។

### ៣.៤ សេវាផ្ទេរប្រាក់ក្នុងស្រុក និងក្រៅប្រទេស

- សេវាផ្ទេរប្រាក់ក្នុងរង្វង់ធនាគារ អេស៊ីលីដា ភីអិលស៊ី រួមមាន ៖
  - ផ្ទេរប្រាក់រវាងគណនីម្ចាស់តែមួយ,
  - ផ្ទេរប្រាក់រវាងគណនីម្ចាស់ផ្សេងគ្នា,
  - ផ្ទេរប្រាក់ទៅអ្នកទទួលគ្មានគណនី,
    + ផ្ទេរប្រាក់ដោយប្រើសំណួរ និងចម្លើយ ឬលេខទូរស័ព្ទ,
    + ផ្ទេរប្រាក់ដោយប្រើជាលិខិតសម្គាល់អត្តសញ្ញាណ,
- សេវាផ្ទេរប្រាក់ពីធនាគារ អេស៊ីលីដា ភីអិលស៊ី ទៅធនាគារផ្សេងនៅក្នុងប្រទេស,
- សេវាផ្ទេរប្រាក់ពីធនាគារ អេស៊ីលីដា ភីអិលស៊ី ទៅធនាគារផ្សេងនៅក្រៅប្រទេស ។

<u>សម្គាល់</u> : រាល់ប្រតិបត្តិការផ្ទេរប្រាក់ តម្រូវឲ្យលោក-លោកស្រីបញ្ជាក់អំពីគោលបំណងនៃការផ្ទេរប្រាក់ ឲ្យបានច្បាស់លាស់ និងផ្តល់នូវឯកសារគាំទ្រ ប្រសិនបើចាំបាច់ ។

## ៤ លេខសម្គាល់អតិថិជន (CIF)

លេខសម្គាល់អតិថិជន មួយ របស់គណនីក្រុមហ៊ុន អាចភ្ជាប់ក្នុងប្រព័ន្ធអេស៊ីលីដាអ៊ីនធើណែត និងធ្វើប្រតិបត្តិការគណនីទាំងអស់របស់ក្រុមហ៊ុន ឬអង្គភាព បានសេវាពេញលេញ ទៅតាមលក្ខខណ្ឌគណនី ឬមុខងារអ្នកប្រើប្រាស់ប្រព័ន្ធ ដូចជា អ្នកបញ្ចូលទិន្នន័យ អ្នកត្រួតពិនិត្យ ឬអនុម័តទិន្នន័យ ដែលបានចាត់តាំងជាលាយលក្ខណ៍អក្សរដោយអ្នកមានសិទ្ធិរបស់ក្រុមហ៊ុន ឬអង្គភាព ។ ក្រោយពីបានភ្ជាប់ប្រព័ន្ធរួច លោក-លោកស្រីអាចបញ្ចូលគណនីមួយ ឬច្រើន ដែលជាកម្មសិទ្ធិរបស់ដៃគូ ដើម្បីរក្សាទុកក្នុងការធ្វើប្រតិបត្តិការផ្ទេរប្រាក់ចូល ដែលមានភាពងាយស្រួល និងរហ័សទាន់ចិត្ត ។

## ៥ លេខសម្ងាត់ និងលក្ខខណ្ឌសុវត្ថិភាព

### ៥.១ លេខសម្ងាត់

- លេខសម្ងាត់ ត្រូវបានជ្រើសរើសដោយលោក-លោកស្រីផ្ទាល់ ហើយអាចផ្លាស់ប្តូរបានតាមតម្រូវការនៅពេលបន្ទាប់ ។ លេខសម្ងាត់នេះមានទម្រង់ជា លេខ, អក្សរ និងសញ្ញា "!, @, #, $, %, &, +, -, =, ?" បង្កើតឡើងដើម្បីឲ្យ លោក-លោកស្រីអាចបង្ការសុវត្ថិភាពផ្ទាល់ខ្លួនបានដោយខ្លួនឯងបន្ថែមទៀត ។
- បន្ទាប់ពីការចុះឈ្មោះក្នុងប្រព័ន្ធអេស៊ីលីដាអ៊ីនធើណែតរួចរាល់ លោក-លោកស្រីនឹងទទួលបាន User ID និងលេខសម្ងាត់បណ្តោះអាសន្ន សម្រាប់ចូលប្រើប្រព័ន្ធលើកដំបូង រួចលោក-លោកស្រីត្រូវប្តូរលេខសម្ងាត់នោះភ្លាម មុននឹងធ្វើប្រតិបត្តិការផ្សេងៗ ។
- លោក-លោកស្រីមិនត្រូវកត់ត្រាលេខសម្ងាត់ ទុកនៅលើវត្ថុអ្វីមួយឡើយ ពោលគឺត្រូវទន្ទេញចាំមាត់ ដើម្បីងាយស្រួលក្នុងការប្រើប្រាស់ និងចៀសវាងអ្នកដទៃលួចប្រើ ។
- លេខ OTP គឺជាលេខសម្ងាត់ដែលមានចំនួន ០៦ខ្ទង់ និងបង្កើតឡើងជាស្វ័យប្រវត្តិដោយ ACLEDA Hard Token ដើម្បីបញ្ជាក់ប្រតិបត្តិការរបស់លោក-លោកស្រី ។
- ការបញ្ចូលលេខសម្ងាត់មិនបានត្រឹមត្រូវ ប្រព័ន្ធនឹងកំណត់រយៈពេលរង់ចាំ សម្រាប់ការបញ្ចូលលេខសម្ងាត់ជាថ្មីម្តងទៀត ។
- ករណីភ្លេច User ID និងលេខសម្ងាត់ផ្ទាល់ខ្លួន លោក-លោកស្រីអាចធ្វើការស្នើសុំ User ID ឬលេខសម្ងាត់ថ្មី តាមរយៈសេវាអេស៊ីលីដាអ៊ីនធើណែត ដោយបំពេញព័ត៌មានឲ្យបានត្រឹមត្រូវ ដូចខាងក្រោម ៖
  - ការស្នើសុំ User ID: ត្រូវបំពេញនូវលេខសម្គាល់អតិថិជន ឈ្មោះ អាសយដ្ឋានអ៊ីម៉ែល និងលេខទូរស័ព្ទដែលបានបញ្ចូលក្នុងប្រព័ន្ធនៅពេលចុះឈ្មោះលើកដំបូង ។
  - ការស្នើសុំលេខសម្ងាត់ថ្មី : ត្រូវបំពេញនូវ User ID, អាសយដ្ឋានអ៊ីម៉ែល និងលេខទូរស័ព្ទ ដែលបានបញ្ចូលក្នុងប្រព័ន្ធនៅពេលចុះឈ្មោះលើកដំបូង ។

<u>បញ្ជាក់</u>: រាល់ប្រតិបត្តិការស្នើសុំ User ID និងការស្នើសុំលេខសម្ងាត់ថ្មី ត្រូវការបញ្ជាក់នូវលេខ OTP ពី ACLEDA Hard Token/ACLEDA Authentication ដើម្បីបញ្ជាក់នូវប្រតិបត្តិការស្នើសុំ ហើយប្រព័ន្ធនឹងផ្ញើ User ID ឬលេខសម្ងាត់ថ្មី ទៅកាន់អាសយដ្ឋានអ៊ីម៉ែល ឬលេខទូរស័ព្ទ របស់អ្នកប្រើប្រាស់សេវាអេស៊ីលីដាអ៊ីនធើណែត ។

### ៥.២ លក្ខខណ្ឌសុវត្ថិភាព

- ត្រូវត្រួតពិនិត្យឧបករណ៍ភ្ជាប់ប្រព័ន្ធអេស៊ីលីដាអ៊ីនធើណែត ឲ្យបានញឹកញាប់ ប្រសិនបើរកឃើញកម្មវិធីដែលមិនធ្លាប់ស្គាល់ ត្រូវសម្អាតភ្លាម ដើម្បីចៀសវាងមេរោគ ឬការបន្លំលួចធ្វើប្រតិបត្តិការគណនី ។
- លោក-លោកស្រី មិនត្រូវចុច ឬភ្ជាប់គេហទំព័រផ្សេងៗដែលសង្ស័យ ឬបញ្ចូលកម្មវិធីមិនស្គាល់នៅក្នុងកុំព្យូទ័រដែលភ្ជាប់ប្រព័ន្ធអេស៊ីលីដាអ៊ីនធើណែតឡើយ ។
- ត្រូវរក្សា ACLEDA Hard Token ឬ ACLEDA Authentication កុំឲ្យអ្នកដទៃលួចបាន និងកុំឲ្យមើលឃើញនៅពេលធ្វើប្រតិបត្តិការ ។
- ត្រូវធ្វើការផ្លាស់ប្តូរលេខសម្ងាត់ឲ្យបានញឹកញាប់ ហើយប្រើឲ្យបានត្រឹមត្រូវ និងមានសុវត្ថិភាព ចៀសវាងអ្នកដទៃលួចបន្លំធ្វើប្រតិបត្តិការគណនី ។
- មិនត្រូវកត់ត្រាលេខសម្ងាត់ទុកកន្លែងណាមួយ ឬកត់ត្រាដោយមិនបំលែងឡើយ ហើយរាល់សំណួរដែលទាក់ទងនឹងលេខសម្ងាត់ មិនត្រូវផ្តល់ចម្លើយជាដាច់ខាត ។
- មិនត្រូវឲ្យគេដឹង ឬមើលឃើញលេខសម្ងាត់នៅពេលប្រើឡើយ ។ នៅពេលបញ្ចូលលេខសម្ងាត់ ត្រូវប្រាកដថាគ្មានអ្នកណាលួចមើល ហើយត្រូវចាកចេញពីប្រព័ន្ធអេស៊ីលីដាអ៊ីនធើណែត ក្រោយពេលធ្វើប្រតិបត្តិការធនាគាររួចភ្លាម ។
- សូមប្រើកុំព្យូទ័រផ្ទាល់ខ្លួនរបស់លោក-លោកស្រី តែប៉ុណ្ណោះ ដើម្បីធ្វើប្រតិបត្តិការសេវាអេស៊ីលីដាអ៊ីនធើណែត ដោយមិនត្រូវប្រើកុំព្យូទ័ររបស់អ្នកដទៃ ឬកុំព្យូទ័ររបស់ហាងអ៊ីនធើណែត អ៊ីនធើណែតកាហ្វេ ឬសណ្ឋាគារឡើយ ។
- ប្រសិនបើមានការសង្ស័យថា មានភាគីផ្សេងចូលប្រើប្រាស់ប្រព័ន្ធអេស៊ីលីដាអ៊ីនធើណែត លោក-លោកស្រីត្រូវជូនដំណឹងមកធនាគារជាបន្ទាន់ ដើម្បីបង្ខាំង ឬចាត់វិធានការផ្សេងៗ តាមលក្ខណៈបច្ចេកទេស ទប់ស្កាត់ការបន្លំធ្វើប្រតិបត្តិការ ឬប្រតិបត្តិការគ្មានការអនុញ្ញាត ។ ប្រសិនបើការជូនដំណឹងធ្វើឡើងតាមរយៈទូរស័ព្ទ លោក-លោកស្រីអាចធ្វើការបញ្ជាក់បន្ថែមជាលាយលក្ខណ៍អក្សរ ឬតាមរយៈអ៊ីម៉ែល ក្នុងរយៈពេល ២ថ្ងៃ នៃថ្ងៃធ្វើការរបស់ធនាគារ ។
- ធនាគារមិនទទួលខុសត្រូវ ចំពោះការខាតបង់ទាំងឡាយ ដែលទាក់ទងនឹងការប្រើប្រាស់សេវាអេស៊ីលីដាអ៊ីនធើណែត ប្រសិនបើលោក-លោកស្រីអនុវត្តមិនបានត្រឹមត្រូវតាមលក្ខខណ្ឌនេះ ។

## ៦ ថ្លៃសេវា

លោក-លោកស្រី ត្រូវបង់ថ្លៃសេវាតាមការកំណត់របស់ធនាគារ រួមមាន ៖

- ថ្លៃសេវាលើប្រតិបត្តិការ ត្រូវកាត់ពីគណនីរបស់លោក-លោកស្រីដោយស្វ័យប្រវត្តិ អាស្រ័យទៅតាមប្រភេទប្រតិបត្តិការនីមួយៗ ដូចជា ផ្ទេរប្រាក់ ទូទាត់ និងផ្សេងៗទៀត បន្ទាប់ពីប្រតិបត្តិការនោះធ្វើបានសម្រេចភ្លាម ។ ដូច្នេះ លោក-លោកស្រីត្រូវត្រួតពិនិត្យថ្លៃសេវាឲ្យបានត្រឹមត្រូវ មុននឹងយល់ព្រមធ្វើប្រតិបត្តិការ ឬចុចបញ្ជូន ឬមុននឹងចុចសញ្ញា "✓" ។
- និងថ្លៃសេវាផ្សេងៗទៀត ដូចមានបង្ហាញនៅក្នុងតារាងថ្លៃសេវា និងការកំណត់ប្រតិបត្តិការសេវាអេស៊ីលីដាអ៊ីនធើណែត ។

## ៧ ការទទួលខុសត្រូវ

៧.១ អាសយដ្ឋានអ៊ីម៉ែលរបស់លោក-លោកស្រីជាអ្នកអភិបាលប្រព័ន្ធ ឬអ្នកប្រើប្រាស់សេវាអេស៊ីលីដាអ៊ីនធើណែត ដែលបានផ្តល់នៅពេលចុះឈ្មោះ ត្រូវបានទទួលស្គាល់ជាផ្លូវការដោយធនាគារ ។ ក្នុងករណី លោក-លោកស្រីត្រូវការប្រើប្រាស់អាសយដ្ឋានអ៊ីម៉ែលផ្សេងពីនេះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរឲ្យធនាគារបានដឹងជាមុន ។

៧.២ សេវាធនាគារតាមប្រព័ន្ធអេស៊ីលីដាអ៊ីនធើណែត អាចធ្វើប្រតិបត្តិការបានដោយស្វ័យប្រវត្តិ ឬមិនស្វ័យប្រវត្តិ ។ គ្រប់ប្រតិបត្តិការដែលមានចែងនៅត្រង់ចំណុច ៣. ខាងលើ លោក-លោកស្រីត្រូវធ្វើការត្រួតពិនិត្យផ្ទាល់ខ្លួន ឲ្យបានត្រឹមត្រូវ និងច្បាស់លាស់លើចំណុចសំខាន់ៗដូចជា អ្នកទទួល ចំនួនទឹកប្រាក់ និងថ្លៃសេវា មុននឹងយល់ព្រមធ្វើប្រតិបត្តិការនោះ (មុននឹងចុចបញ្ជូន ឬចុចសញ្ញា "✓") ។ ចំពោះប្រតិបត្តិការមិនស្វ័យប្រវត្តិ ជាកម្មវត្ថុនៃការត្រួតពិនិត្យរបស់ធនាគារ នៅក្នុងម៉ោងបម្រើសេវាប៉ុណ្ណោះ ទោះបីលោក-លោកស្រីបានដាក់សំណើនៅក្នុងប្រព័ន្ធពីពេលណាក៏ដោយ ហើយសំណើនោះនឹងទទួលអនុវត្តបន្តដោយបុគ្គលិកទទួលខុសត្រូវ ទៅតាមនីតិវិធីដែលមានស្រាប់ ។ ដូច្នេះ ប្រសិនបើមានការសង្ស័យ ឬមិនបានទទួលសេវាក្នុងពេលបន្ទាប់ លោក-លោកស្រីអាចទាក់ទងមកការិយាល័យសាខាសាមី ឬការិយាល័យទំនាក់ទំនងអតិថិជន ដើម្បីបញ្ជាក់បន្ថែមឲ្យបានច្បាស់លាស់ ។

៧.៣ លោក-លោកស្រី ត្រូវទទួលខុសត្រូវទាំងស្រុងលើការខូចខាតទ្រព្យសម្បត្តិ ឬបាត់បង់ទឹកប្រាក់ក្នុងគណនីផ្ទាល់ខ្លួន ឬគណនីរបស់អ្នកផ្សេង ឬគណនីរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ព្រមទាំងទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ប្រសិនបើលោក-លោកស្រីបានប្រព្រឹត្តដោយធ្វេសប្រហែស ឬការសាកល្បងធ្វើប្រតិបត្តិការផ្សេងៗ ការលុកលុយរុករក ការកែបន្លំទិន្នន័យ ការលួចបន្លំដោយផ្ទាល់ ឬដោយប្រយោល តែម្នាក់ឯង ឬដោយមានការចូលរួមពីអ្នកដទៃ ទោះបីការប្រព្រឹត្តនោះដោយចេតនា ឬអចេតនាក៏ដោយ ។

៧.៤ លោក-លោកស្រី យល់ព្រមអនុវត្តទៅតាមគោលការណ៍ ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទាក់ទងនឹងការប្រើប្រាស់សេវាអេស៊ីលីដាអ៊ីនធើណែត ដូចជា ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ជាដើម ។

៧.៥ ដោយការព្រមព្រៀងជាមួយលក្ខខណ្ឌនៃការប្រើប្រាស់នេះ លោក-លោកស្រីបានយល់ស្របថា ធនាគារមានសិទ្ធិក្នុងការពន្យារពេល បង្ខាំង ឬបដិសេធធ្វើប្រតិបត្តិការ ដោយមិនទទួលខុសត្រូវ ប្រសិនបើធនាគាររកឃើញ ឬសង្ស័យថា ៖

- ប្រតិបត្តិការរបស់លោក-លោកស្រី ផ្ទុយនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬប្រទេសដទៃទៀត ។
- ប្រតិបត្តិការរបស់លោក-លោកស្រី ជាប់ពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលជាមួយបុគ្គល ឬអង្គភាពដែលត្រូវបានហាមឃាត់ ឬទៅ-មកពីប្រទេសទណ្ឌកម្មសេដ្ឋកិច្ច ឬជាប្រយោជន៍បម្រើដល់សកម្មភាពល្មើសច្បាប់ ។

៧.៦ លោក-លោកស្រី ត្រូវយល់ព្រមចាត់វិធានការប្រុងប្រយ័ត្នគ្រប់ពេលវេលាដើម្បីធានានូវសុវត្ថិភាព សន្តិសុខ និងសុចរិតភាពនៃគណនី និងប្រតិបត្តិការរបស់លោក-លោកស្រី នៅពេលប្រើប្រាស់សេវាអេស៊ីលីដាអ៊ីនធើណែត ។

៧.៧ លោក-លោកស្រី ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះអ្នកប្រើប្រព័ន្ធ និងលេខសម្ងាត់ ឲ្យបានត្រឹមត្រូវ និងមានសុវត្ថិភាពខ្ពស់បំផុត ចៀសវាងអ្នកដទៃលួចបន្លំធ្វើប្រតិបត្តិការគណនី ។

៧.៨ លោក-លោកស្រី ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការខូចខាត ឬការបាត់បង់ បណ្តាលមកពីប្រតិបត្តិការដែលគ្មានការអនុញ្ញាត រួមទាំងការផ្ញើព័ត៌មានមិនត្រឹមត្រូវ ជាដើម ។

៧.៩ ធនាគារនឹងអនុវត្តតាមការណែនាំ ឬប្រតិបត្តិការដែលធ្វើឡើងតាមរយៈអ្នកប្រើប្រព័ន្ធ ។ ក្នុងករណីមានការខកខាន ឬការរអាក់រអួលក្នុងការឆ្លើយតបនូវសំណើរបស់លោក-លោកស្រី ដោយសារបញ្ហាបច្ចេកទេសបណ្តាញព័ត៌មានវិជ្ជា លោក-លោកស្រីត្រូវជូនដំណឹងតាមរយៈទូរស័ព្ទ ឬមកកាន់ការិយាល័យធនាគារដែលនៅជិតបំផុត ដើម្បីបន្តប្រតិបត្តិការនោះ ។

៧.១០ ធនាគារមានសិទ្ធិត្រួតពិនិត្យ និងអនុវត្ត ឬមិនអនុវត្តតាមការណែនាំ ឬប្រតិបត្តិការរបស់លោក-លោកស្រីដោយអនុលោមតាមគោលការណ៍ផ្ទៃក្នុង ឬបទប្បញ្ញត្តិជាធរមាន ។

៧.១១ លោក-លោកស្រី ត្រូវទទួលខុសត្រូវទាំងស្រុងនូវរាល់ការខូចខាត ឬការបាត់បង់ ដែលបណ្តាលមកពី ៖

- ការយឺតយ៉ាវ ឬខកខានមិនបានជូនដំណឹងដល់ធនាគារនូវរបាយការណ៍ដែលមានភាពមិនស្របគ្នា ឬការចុះបញ្ជីនៅក្នុងរបាយការណ៍គណនីមិនបានត្រឹមត្រូវ ដូចក្នុងចំណុច ១២.១ ខាងក្រោម ។
- ការធ្វេសប្រហែស ឬក្លែងបន្លំធ្វើប្រតិបត្តិការ ដូចជាការប្រើប្រាស់ User ID និងលេខសម្ងាត់ មិនត្រឹមត្រូវ តាមលក្ខខណ្ឌសុវត្ថិភាព ជាដើម ។
- ការខកខានមិនបានរាយការណ៍ជូនធនាគារនូវប្រតិបត្តិការដែលមិនមានការអនុញ្ញាត ។

## ៨ ការកែប្រែ ឬធ្វើមោឃភាព

៨.១ ដើម្បីកែប្រែ ឬមោឃភាពសេវាអេស៊ីលីដាអ៊ីនធើណែតបាន លោក-លោកស្រីត្រូវជូនដំណឹងមកធនាគារជាលាយលក្ខណ៍អក្សរតាមរយៈអ៊ីម៉ែល ឬបំពេញពាក្យស្នើសុំកែប្រែ ឬធ្វើមោឃភាពដោយផ្ទាល់ នៅការិយាល័យធនាគារ ។

៨.២ ធនាគារមានសិទ្ធិទទួលយកសំណើសុំធ្វើមោឃភាព ឬមិនទទួលយក ក្នុងករណីលោក-លោកស្រី មានបំណុល ឬមានវិវាទមិនទាន់ដោះស្រាយចប់ ឬដោយមូលហេតុជាក់លាក់ណាមួយ ។ យ៉ាងណាក៏ដោយ លោក-លោកស្រីត្រូវទូទាត់សំណង ឬចំណាយផ្សេងៗដែលកើតឡើង ឲ្យបានរួចរាល់ មុនពេលការធ្វើមោឃភាពសេវាអេស៊ីលីដាអ៊ីនធើណែត ។

៨.៣ម្យ៉ាងទៀត សេវាអេស៊ីលីដាអ៊ីនធើណែតរបស់លោក-លោកស្រី នឹងត្រូវបញ្ឈប់ដោយមិនមានការជូនដំណឹងជាមុនឡើយក្នុងករណីគណនីភ្ជាប់ប្រព័ន្ធក្លាយជាគណនីនៅស្ងៀមនិងគ្មានសកម្មភាព ឬគណនីប្រភពបានបិទ ឬហេតុផលណាមួយដែលធ្វើឲ្យប៉ះពាល់ដល់អត្ថប្រយោជន៍ និងកេរ្តិ៍ឈ្មោះរបស់ធនាគារ ។

## ៩ ការកែប្រែព័ត៌មាន

ធនាគារនឹងជូនដំណឹងលោក-លោកស្រីជាមុនរហូតដល់ ៣០ថ្ងៃ ក្នុងករណីមានការកែប្រែថ្លៃសេវា បន្ថែម លុបចោល ឬកែប្រែចំណុចណាមួយនៃលក្ខខណ្ឌនេះ ដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិ និងការទទួលខុសត្រូវរបស់លោក-លោកស្រី តាមរយៈមធ្យោបាយណាមួយ ក្នុងចំណោមខាងក្រោម ៖

- ផ្ញើសារទៅកាន់អាសយដ្ឋានអ៊ីម៉ែលរបស់លោក-លោកស្រី ដោយផ្ទាល់,
- ផ្សព្វផ្សាយជាសាធារណៈតាមរយៈសារព័ត៌មាន,
- ជូនដំណឹងនៅការិយាល័យធនាគារ ឬ
- ជូនដំណឹងតាមរយៈគេហទំព័ររបស់ធនាគារ ។

## ១០ ការទូទាត់សំណង

លោក-លោកស្រី យល់ព្រមដោយឥតលក្ខខណ្ឌ ក្នុងការទូទាត់សំណងមកធនាគារនូវរាល់ការខូចខាត បាត់បង់ ការទាមទារសំណង ឬការចំណាយផ្សេងៗដែលធនាគារទទួលរង ទាក់ទងនឹងការប្រើប្រាស់សេវាអេស៊ីលីដាអ៊ីនធើណែត និងការអនុវត្តន៍បំពានលើកិច្ចព្រមព្រៀងនេះ រួមទាំងការខកខានមិនបានចាត់វិធានការទប់ស្កាត់ការធ្វើប្រតិបត្តិការសេវាអេស៊ីលីដាអ៊ីនធើណែតដោយគ្មានការអនុញ្ញាត ឬប្រតិបត្តិការក្លែងបន្លំ ។

## ១១ ការដោះស្រាយវិវាទ និងវិធានការច្បាប់

**១១.១** រាល់បញ្ហាផ្សេងៗកើតមានឡើងខុសប្រក្រតី ទាក់ទងនឹងសមតុល្យក្នុងគណនីដែលភ្ជាប់ប្រព័ន្ធអេស៊ីលីដាអ៊ីនធើណែត លោក-លោកស្រី ត្រូវជូនដំណឹងមកធនាគារឲ្យបានមុនរយៈពេល ៣០ថ្ងៃ បន្ទាប់ពីថ្ងៃប្រតិបត្តិការបានកើតឡើង ។ ក្នុងករណីមិនបានជូនដំណឹងមកធនាគារទាន់ពេល ធនាគាររក្សាសិទ្ធិមិនដោះស្រាយបញ្ហាជូនឡើយ ។

**១១.២** ចំពោះបញ្ហាដែលកើតមានទាក់ទងនឹងធនាគារក្រៅប្រទេស ធនាគាររក្សាសិទ្ធិក្នុងការដោះស្រាយបញ្ហាជូន ដោយអនុលោមតាមគោលការណ៍អន្តរធនាគារ ដែលមានរយៈពេលរហូតដល់ ៦០ថ្ងៃ បន្ទាប់ពីថ្ងៃធ្វើប្រតិបត្តិការបានកើតឡើង ។

**១១.៣** លក្ខខណ្ឌនេះ ធ្វើឡើងដោយអនុលោមទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ ក្នុងករណីមានវិវាទកើតឡើង ភាគីទាំងពីរព្រមព្រៀងគ្នាដោះស្រាយដោយសន្តិវិធីតាមរយៈការចរចា ។ ប្រសិនបើ ការចរចាពុំអាចដោះស្រាយបាន ភាគីទាំងពីរសុខចិត្តដោះស្រាយវិវាទនោះតាមផ្លូវតុលាការ ។ រាល់ការចំណាយលើការដោះស្រាយវិវាទ ជាបន្ទុករបស់ភាគីដែលរំលោភលើការអនុវត្តលក្ខខណ្ឌនេះ ។

## ១២ ការបង្ហាញព័ត៌មាន

**១២.១** ធនាគាររក្សាសិទ្ធិក្នុងការផ្តល់នូវព័ត៌មានដែលទាក់ទងនឹងគណនីរបស់លោក-លោកស្រី ក្នុងករណីដូចខាងក្រោម ៖

- តម្រូវការចាំបាច់របស់អាជ្ញាធរមានសមត្ថកិច្ច ដូចជា ធនាគារជាតិ នៃ កម្ពុជា ឬតុលាការ ជាដើម លើកលែងតែមានឯកសារប្តឹងជំទាស់តាមផ្លូវច្បាប់ពីតុលាការ ។
- ប្រើប្រាស់ក្នុងសវនកម្ម និង
- ករណីផ្សេងទៀត ដែលមានការឯកភាពពីលោក-លោកស្រី និងស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

**១២.២** ធនាគាររក្សាសិទ្ធិក្នុងការប្រើប្រាស់ព័ត៌មាននៅក្នុងពាក្យស្នើសុំ និងសម្រាប់ការស្រាវជ្រាវ រួមមាន របាយការណ៍អតិថិជន សកម្មភាពផ្សព្វផ្សាយទីផ្សារធ្វើឡើងដោយធនាគារ/ក្រុមហ៊ុនបុត្រសម្ព័ន្ធ ។

## ១៣ ម៉ោងបម្រើសេវា

**១៣.១** ម៉ោងបម្រើសេវានៅតាមការិយាល័យធនាគារ ចាប់ពីម៉ោង ៧:៣០នាទី ដល់ម៉ោង ១៦:៣០នាទី, ០៥ថ្ងៃក្នុងមួយសប្តាហ៍ ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ហើយឈប់សម្រាកនៅថ្ងៃសៅរ៍-អាទិត្យ និងថ្ងៃបុណ្យជាតិ និងអន្តរជាតិ ។

**១៣.២**
- ប្រតិបត្តិការស្វ័យប្រវត្តិ "STP" (Straight Through Process) : បម្រើសេវា ២៤ម៉ោងក្នុងមួយថ្ងៃ ០៧ថ្ងៃក្នុងមួយសប្តាហ៍ លើកលែងតែការបិទប្រព័ន្ធដើម្បីជួសជុលតាមកាលវិភាគ ករណីប្រព័ន្ធអាក់រអួល ឬមិនដំណើរការ ដោយចៃដន្យ ។
- ប្រតិបត្តិការមិនស្វ័យប្រវត្តិ "NSTP" (Non-straight Through Process) : លោក-លោកស្រី អាចដាក់សំណើបង្កើត Corporate User ឬធ្វើប្រតិបត្តិការសេវាធនាគារ ២៤ម៉ោងក្នុងមួយថ្ងៃ ៧ថ្ងៃក្នុងមួយសប្តាហ៍ ប៉ុន្តែធនាគារនឹងធ្វើការត្រួតពិនិត្យ និងអនុមតិ រៀងរាល់ថ្ងៃធ្វើការ ចាប់ពីម៉ោង ៧:៣០នាទី ដល់ម៉ោង ១៦:០០នាទី លើកលែងការផ្ទេរប្រាក់ពីធនាគារ អេស៊ីលីដា ភីអិលស៊ី ទៅធនាគារផ្សេងនៅក្នុងប្រទេសកម្ពុជា ដែលត្រូវធ្វើការត្រួតពិនិត្យ និងអនុម័ត នៅថ្ងៃធ្វើការ ចាប់ពីម៉ោង ៧:៣០នាទី ដល់ម៉ោង ១៤:៣០នាទី ។ ចំពោះសំណើសុំធ្វើប្រតិបត្តិការដែលកើតឡើង ឬធ្វើក្រោយម៉ោងដែលបានកំណត់ខាងលើ ត្រូវអនុវត្តដូចខាងក្រោម ៖

- ករណីប្រតិបត្តិការដែលមិនមានបញ្ជាក់ និង/ឬមិនទាន់ដល់ថ្ងៃប្រសិទ្ធភាព នឹងទទួលបានការអនុមតិនៅថ្ងៃធ្វើការបន្ទាប់ ។
- ករណីប្រតិបត្តិការដែលមានប្រសិទ្ធភាពនៅក្នុងថ្ងៃ នឹងត្រូវបានបដិសេធដោយធនាគារ ហើយអស់សុពលភាពនៅពេលនោះ ។ ដូច្នេះលោក-លោកស្រី ត្រូវដាក់សំណើសារជាថ្មី ។

សម្គាល់ : - ប្រតិបត្តិការសេវាមិនស្វ័យប្រវត្តិរួមមាន ៖

- សេវាផ្ទេរប្រាក់ក្នុងវង្វង់អេស៊ីលីដា ដែលមានទំហំទឹកប្រាក់ដូចខាងក្រោម ៖
  - គណនីក្រុមហ៊ុន ធំជាង ៥០,០០០ ដុល្លារ ឬ សមមូល ឡើងទៅ ។
  - ផ្ទេរប្រាក់ទៅអ្នកទទួលគ្មានគណនី ធំជាង ១,០០០ ដុល្លារ ឬ សមមូល ឡើងទៅ ។
  - ធនាគាររក្សាសិទ្ធិក្នុងការកែប្រែទំហំទឹកប្រាក់ផ្ទេរមិនស្វ័យប្រវត្តិខាងលើ ទៅតាមស្ថានភាពជាក់ស្តែង ។
- សេវាផ្ទេរប្រាក់ទៅធនាគារផ្សេង នៅក្នុងប្រទេសកម្ពុជា ។
- សេវាផ្ទេរប្រាក់ទៅក្រៅប្រទេស តាមប្រព័ន្ធ SWIFT ។
- សេវាស្នើសុំប្រើប្រាស់ផលិតផល និងសេវាកម្មផ្សេងៗរបស់ធនាគារ (ចំណុច ៣.៣) ។

- ប្រតិបត្តិការដែលទាក់ទងនឹងរូបិយប័ណ្ណផ្សេងគ្នា ធនាគារនឹងគិតអត្រាប្តូរប្រាក់ដែលមានសុពលភាព នៅថ្ងៃដែលធនាគារអនុម័តប្រតិបត្តិការនោះ ។

១៣.៣ ម៉ោងបម្រើសេវា តាមរយៈការិយាល័យទំនាក់ទំនងអតិថិជន (Call Center) គឺធ្វើឡើងជារៀងរាល់ថ្ងៃ ឬ ២៤ម៉ោងក្នុងមួយថ្ងៃ ៧ថ្ងៃក្នុងមួយសប្តាហ៍ ។ ដូច្នេះ ករណីលោក-លោកស្រីមានចម្ងល់ ឬបញ្ហាផ្សេងៗ សូមទំនាក់ទំនងតាមរយៈទូរស័ព្ទលេខ : +៨៥៥ (0) ២៣ ៩៩៤ ៤៤៤ / (0)១៥ ៩៩៩ ២៣៣ ឬអ៊ីម៉ែល : inquiry@acledabank.com.kh ។

## ១៤ លក្ខខណ្ឌផ្សេងៗ

១៤.១ លក្ខខណ្ឌនៃការប្រើប្រាស់នេះ សរសេរជាភាសាខ្មែរ និងភាសាអង់គ្លេស ប្រសិនបើចំណុចណាមួយមានអត្ថន័យខុសគ្នារវាងភាសាខ្មែរ និងភាសាអង់គ្លេស នោះលក្ខខណ្ឌជាភាសាខ្មែរ ត្រូវយកជាការបាន។

១៤.២ លក្ខខណ្ឌនៃការប្រើប្រាស់នេះ ត្រូវអនុលោមទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ខ្ញុំ/យើងខ្ញុំ ពិតជាបានអាន និងយល់ព្រមគ្រប់លក្ខខណ្ឌដែលបានបញ្ជាក់ខាងលើនេះ ។

ថ្ងៃ........... ............. ខែ............ ឆ្នាំ...... .......ស័ក ព.ស. ..........

......................ថ្ងៃទី........... ខែ.......... ឆ្នាំ..........

ហត្ថលេខា ឬស្នាមមេដៃស្តាំ